# កែវភ្នែកស្រី (ពាក្យប្រាំពីរ)

-កែវភ្នែកមានពិសបិតព្រួញស្នេហ៍ បាញ់ឆក់ឆាបតែមុំបេះដូង
ពិសភ្នែកសក្តិសិទ្ធិរឹតឱ្យខ្លួង ចងជាចម្រូងដោតហាលថ្ងៃ ។
-កែវភ្នែកពិសពុលកប់ល្បិចស្នេហ៍ ដុះជាច្រែះស្នេហ៍ឱ្យស្រមៃ
សម្លឹងចំម្តងក្រងអាល័យ ភ្នែកថ្ងៃឱ្យនឹកភ្លេចមិនបាន ។
-កែវភ្នែកកំណាចខាបឱ្យស្ទុគ្រ កាច់ចិត្តបំបាក់ស្លាប់មុនប្រាណ
ឱ្យស្លុតរន្ធត់លែងក្លាហាន ទន់ជ្រាយហួសស្មានព្រោះតែភ្នែក
-ភ្នែកស្រីប្រៀបបាននឹងអាវុធ ប្រយុទ្ធដួងចិត្តឱ្យយំយែក
វះជ្រៀកសួតថ្លើមក្លាយអូរព្រែក ខាំញែករហែកឱ្យខ្លោចផ្សារ ។
-កែវភ្នែកពិតពិសពេលមើលចំ ទោះខំប្រឹងចៀសមិនបានការ
កែវភ្នែកចាក់សោរចងឱ្យរ៉ា មិឱ្យទៅណាឆ្ងាយបានឡើយ ។
-ឱកែវភ្នែកអើយ កែវភ្នែកស្រី ប្រណីលែងបងណាត្រាណត្រើយ
ព្រោះតែកែវភ្នែកទ្រូងឥតស្បើយ មិនដែលល្ហែល្ហើយនឹកភ្នែកស្រី ។

ពៅ សុខ

០១២ ៩៨៨ ១៧៦